**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

**សូមគោរពជូន**
**លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី អនុប្រធានទី២ នៃរដ្ឋសភា**

**លោកជំទាវកិត្តិសង្គហបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសដ៏មហាប្រសើរប្រកបដោយក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាក្រៃលែង និងសូមគោរពជូនពរ បវរសួស្តី សិរីមង្គល វិបុលសុខ ដ៏មហាប្រសើរគ្រប់ប្រការជូន **លោកជំទាវកិត្តិសង្គហបណ្ឌិត** សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា កាយពលមាំមួន និងជន្មាយុយឺនយូរ ដើម្បីចូលរួមចំណែកដឹកនាំស្ថាប័នរដ្ឋសភាឱ្យសម្រេចបាននូវជ័យជម្នះធំៗជាច្រើនថែមទៀត ធានាដល់ដំណើរការនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រទេសឱ្យកាន់តែមានភាពសម្បូរសប្បាយ និងសុភមង្គលជូនប្រជាជាតិកម្ពុជានៅក្រោមដំបូលនៃសុខសន្តិភាព និងភាតរភាពជាតិ។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លា នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក តេជៈបារមីទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** សូមយាងប្រោសប្រទានសព្ទសាធុការពរជូន **លោកជំទាវកិត្តិសង្គហបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** មានសុខភាពល្អបរិបូរណ៍ បវរសួស្តី សិរីមង្គលគ្រប់ប្រការ និងសូមសម្រេចបាននូវព្រះពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវកិត្តិសង្គហបណ្ឌិត អនុប្រធានទី២ នៃរដ្ឋសភា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ ចន្ទ ៥ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រំ.សុខា